# សិលាចារឹកសំស្ក្រឹតវត្តគិរីស្ដេចគង់ (សុវណ្ណភូមិ)

កន្លងមក លោក ហ៊ុន ឈុនតេង ធ្លាប់បានផ្សាយដោយសង្ខេបខ្លះៗមកហើយ នៅក្នុងបណ្ដាញ AMS អារ្យធម៌ខ្មែរ ស្ដីពី "**អត្ថន័យសិលាចារឹកសុវណ្ណភូមិ K.1419**"។ ប៉ុន្តែ នៅក្នុងអត្ថបទនេះ យើងសូមបង្ហាញសេចក្ដីនៃអត្ថបទទាំងមូលតែម្ដង ដើម្បីជាចំណែកមួយចូលរួមក្នុងការសិក្សាសិលាចារឹកសំស្ក្រឹតបុរាណនៅកម្ពុជា។ វត្តគិរីស្ដេចគង់ មានទីតាំងស្ថិតនៅឃុំស្វាយចចឹប ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ជាអតីតប្រាសាទបុរាណនៅក្នុងស.វ.ទី៧ ដែលសព្វថ្ងៃគេបានរកឃើញគ្រឹះរបស់ប្រាសាទ បន្ទាប់ពីការធ្វើកំណាយសង្គ្រោះរបស់នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិសាស្ត្រ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ សិលាចារឹកសំស្ក្រឹតនៅវត្តគិរីស្ដេចគង់ដែលយើងលើកមកសិក្សានៅពេលនេះ ជាទូទៅគេស្គាល់ថា "**សិលាចារឹកសុវណ្ណភូមិ**" ដោយសារក្នុងសេចក្ដីនៃចារឹកមានរំលេចនូវពាក្យ "**សុវណ្ណភូមិ**"។

អត្ថបទសិលាចារឹកសំស្ក្រឹតនេះ ផ្សព្វផ្សាយឡើងដំបូងនៅរវាងចុងឆ្នាំ២០១៧ ដើមឆ្នាំ២០១៨ ដោយលោក **វង់ សុជាវ៉** នៅក្នុងគណនេយ្យហ្វេសបុករបស់លោកផ្ទាល់ និងតាមរយៈការឡើងធ្វើបទសម្ភាសន៍អំពីរបកគំហើញនៃសិលាចារឹកនេះនៅតាមស្ថានីយទូរទស្សន៍ និងវិទ្យុក្នុងស្រុក ដោយមានការចូលរួមពីសំណាក់ លោក **ហ៊ុន ឈុនតេង** និងលោកស្រី **ធោម គន្ធា** ផងដែរ។ ក្រោយមកទៀត ក៏មានព្រះសង្ឃខ្មែរនៅបរទេសមួយចំនួន ចាប់អារម្មណ៍យកសិលាចារឹកនេះទៅសិក្សាបន្ត ដូចជា ព្រះគម្ដែងសង្ឃ **សែម ឈុនលី** ព្រះគម្ដែងសង្ឃ **អេង សុគង់**។ នៅក្នុងឆ្នាំ២០១៨ លោក **លី រស្មី** និងរូបខ្ញុំបាទ ធ្លាប់បានបកប្រែសិលាចារឹកនេះទាំងមូលម្ដងរួចមកហើយ ដោយបានផ្សព្វផ្សាយនៅក្នុងបណ្ដាញទំនាក់ទំនងសង្គម តាមរយៈគណនេយ្យហ្វេសបុករបស់លោក លី រស្មី ។ លុះមកដល់ឆ្នាំ២០១៩ លោកស្រី ធោម គន្ធា លោក វង់ សុជាវ៉ និងលោក ហ៊ុន ឈុនតេង បានចេញផ្សាយអត្ថបទអំពីសិលាចារឹកនេះនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំទី៦៦ លេខ៤ (លេខពិសេស) របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

សិលាចារឹកវត្តគិរីស្ដេចគង់ ចារឹកឡើងនៅមហាសករាជឆ្នាំ ៥៥៥ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៦៣៣ ក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧)។ សិលាចារឹកនេះ មានចំនួន ២២ បន្ទាត់ ចារនៅលើប្រភេទថ្មស្រទាប់ដែលគេយកមកធ្វើជាមេទ្វារ និងមានខ្នាតសរុប ១០០ស.ម. x ៥៥ស.ម. ដោយសព្វថ្ងៃចុះបញ្ជីលេខ K.1419។ ខ្លឹមសាររួមរបស់សិលាចារឹកនេះ អាចសង្ខេបមកដូចខាងក្រោម៖

អត្ថបទដោយ៖ កំ វណ្ណាវ៉

- *ផ្នែកខាងលើពោលអួតសរសើរដល់ទេពក្នុងព្រហ្មញ្ញសាសនា និងការរួមបញ្ចូលគ្នារវាងទេពសំខាន់ពីរ គឺព្រះឥសូរ និងព្រះវិស្ណុ ដែលយើងតែងស្គាល់ថា "ហរិហរ" និងព្រំដែនរដ្ឋបាលរបស់ព្រះញ្ញសានវរ្ម័នទី១ គឺសុវណ្ណភូមិព័ទ្ធជុំវិញដោយសមុទ្រ និងរៀបរាប់ពីមូលនិធីរបស់ព្រៅឯគ្គ ថ្វាយចំពោះព្រះស្រីបុស្ករេស មានដីស្រែ គោ ក្របី ដោយមានបញ្ជាក់ចំនួនយ៉ាងជាក់លាក់។ មានស្លោកដាក់បណ្តាសាដល់អ្នកលបលួចយកទ្រព្យសម្បត្តិរបស់ទេពឱ្យធ្លាក់នរក និងបញ្ជាក់កាលបរិច្ឆេទឆ្នាំ៥៥៥ ស.ក. ខាងដើមខ្នើត ខែចេត្រ ព្រះចន្ទ្រសោយឫក្សអស្វនីនក្សត្រ ដោយរាប់ចាប់ពីតុលរាសី រហូតដល់មិថុនរាសី។*
- *ស្លោកចុងក្រោយបង្ហាញជាម៉ោងពេលវេលាថា "សុភលគ្ន" ជាពេលដ៏ល្អក្នុងការប្រតិស្ឋាន ដោយការកំណត់យកចំពេលព្រះអាទិត្យរះឡើងក្នុងកុម្ភៈរាសី គោចរឈានកន្លងចូលដល់មិនារាសី ចាបក្រមជាអក្សរកោងនៃចក្ររាសី ដែលជាពេលប្រតិស្ឋានព្រះស្រី ហរ គ្រឹស្ណ។*
- *ជាទូទៅ ក្នុងតារាសាស្ត្រកំណត់ខែកុម្ភៈមាន ៤ មហានាទី គុណ ២៤ ស្មើ ៩៦នាទី ត្រូវ១ម៉ោង ៣៦នាទី។ ក្នុងមិនារាសីមាន ៥ មហានាទី គុណ ២៤ ស្មើ ១២០នាទី ត្រូវជា ២ម៉ោង។ លគ្នឈានកន្លងពីកុម្ភៈរាសី ទៅមិនារាសី យក១ម៉ោង៣៥នាទី គុណ ២ម៉ោងស្មើនឹង ៣ម៉ោង៣៦នាទី។ ព្រះអាទិត្យរះនៅម៉ោង៦ព្រឹក បូក៣ម៉ោង៣៦នាទី ត្រូវជាម៉ោង ៩កន្លះព្រឹក។ ដូច្នេះ គេប្រតិស្ឋានរូបព្រះស្រី ហរ គ្រឹស្ណ នៅម៉ោង ៩ កន្លះព្រឹក។*

## អត្ថបទពាក្យចារឹក

| | | |
|---|---|---|
| ១. | ជយត្យ ជីគសិ សុរមៅលិ ក្វជ | ចូឌាមណីនិ វិស្ផុរទុឌ្ឋយូញ្ចានិ |
| | វិជិត្យ តនិ មូធ្ន៌សុ យស្យ ចាឝ | ឆ១ ប្រភា វិម្ភ្មត ចន្ទ្រកាន្តិះ។ |
| ២. | ត្រិភានវិម្ល្វជយតសិ សុរេកៅ | យយោតិ ឝរីរាធ៌្ធ សមាគមេឝ |
| | អវ៌្យភ្វាមរមោណាវេមុ | វិកុត្វមេកត្វមនេកតា ច ។ |
| ៣. | វក្ត្រេណ ជីត ត្រិ រុរសា ច បឝ្ក្យាំ | កុ+ចាលិតា ស្មត បតិនិ អតិភាត្យាតិ |
| | ក្បិទ្ធាហិទ្វាំ យឝហន្ត ឝន្យា | យំ គីត្តិ៌រ ឧទ្ទិត្យ វនេឝិ ឥតីវ ។ |
| ៤. | សមុទ្របយ៌្យន្តសុវណ៌្ណភូមិ | ប្វម្ល៉ែកាវាជេន្ទ្របរាក្រមត្រឹះ |
| | សមស្តសាមន្តគិរោឌ្ធតាដ្វត | ត្រិភានវម្ម៌ាជយតិក្បិភីតះ ។ |

*អត្ថបទដោយ៖ កំ វណ្ណាវ៉ា*

| | | |
|---|---|---|
| ៥. | តស្យាបិភ្ឫត្យសិ សមជត្តសំជ្ញាំ | ព្រើឯត្តឥត្យាត្នកុរុប្រិធិម្នាំ |
| | តតិ ប្វ៌ដេ ស្ថាបិតវត្យជាជី | ត្រីបុប្ករេតំ ប្រថមំ សុរាណាំ។ |
| ៦. | កុរេសិ ស្វភក្ត្យា ភគិជី មុរារេះ | ត្រីគវ្វិគោវិន្ទមតិម្ពិបតិ សះ |
| | ស្វយម្ភុទេវីករកោគរាជាំ | តេជាបិ សំស្ថាបិត ឯកកោគះ ។ |
| ៧. | តេឞាំ សុរាណាមិ ឥហ ភ្ឫត្យសំខ្យា | សំបិណ្ឌិតា ស្យាត ត្រិគតី ករាញ ច |
| | សា ត្រិង្កតី ក្សេត្រកមាហិឞាណាំ | ប្រត្យេកមារាម ឥតិ ត្រយាណាំ ។ |
| ៨. | ឯតានិ គោភូជន ប្វ៌កាណិ | សភ្វ៌ាណិ ជម្នាត្តំ ឧចាដ្ជីតានិ |
| | បទេ កុលាជាំ ស្វកុលៃកជីចោ | ព្រើឯត្ត ជាមានិតទេវតាក្យះ ។ |
| ៩. | យទ្វា ត្រយាណាមិ ឥហ ទេវតាជាំ | ឧត្វា ជនំ យោ ហរតិ ស្ន លោភាតិ |
| | សហ ប្រសូត្យា និរយេ និមជ្ជេ | ជាសំ ប្វាតិ ស្ថាវរ ជង្គ មាជាំ ។ |
| ១០. | សមា គកោដ្វស្យ គរេមុ រាណៃរ៑ | វ្វិនិក៌្តា ចៃត្រ សិតានិរាត្រិះ |
| | យជាត្វិជី គីតកាពេទុយាត្រិ | តុលោទយោមៃថុនភាគ យុក្តះ ។ |
| ១១. | មីជាជវីជា ឈមមាក៌្តកុម្ភ | ចាបក្រមស្ថាគិ កុភលគ្ន ជាស្តេ |
| | ( ស្វ )យ៉ោទយគិ ត្រីហរក្ម្ពម្វ៌ត្តិមិ | អតិម្ពិបត្តាំ វិជិដេហ យជា ។ |

**បំណកប្រែ**

*១. ពន្លឺភ្លឺតាមចន្លោះព្រះនខា នៃព្រះបាទាទាំងគូរ ដូចជារស្មីនៃព្រះចន្ទ្រ បានភ្លឺឈ្នះអស់ពន្លឺត្បូងចូឌាមណីលើកំពូលមកុដនៃពួកទេវតាឡាំងឡាយ ហើយបានភ្លឺចែងចាំងថ្លៃលធ្លាត់ពាសពេញព្រះសិរិសាទាំងអស់នៃទេពតាទាំងនោះ (ភាពអស្ចារ្យយ៉ាងនេះ) មានប្រាកដចំពោះព្រះអាទិទេពអង្គណា រីព្រះអាទិទេព (គឺព្រះហរិហរ) ជាអធិបតីអង្គនោះរមែងមានជ័យជម្នះ។*

*២. ការស្នងរូប ជាភាវៈមានអំណាចខ្លាំងក្លាក្តី ជាភាវៈតែម្យ៉ាង និងយ៉ាងច្រើនអនេកទៀតក្តី បានកើតមានលើមាណព (ក្មេងកំលោះ) ដែលមានជីវិតអមតៈ ព្រោះតែការរួមផ្សុំផ្គុំគ្នានៃព្រះសរីរាង្គម្នាក់ពាក់កណ្តាលរបស់ព្រះអាទិទេពទាំងពីរព្រះអង្គ រីព្រះអាទិទេពទាំងពីរព្រះអង្គដែលជាអធិបតិនៃពួកទេវតា គឺព្រះស្រីឦសាន (ព្រះសិវ) និង ព្រះវិស្ណុ (ព្រះនារាយណ៍) រមែងមានជ័យជម្នះ។*

*៣. មួយវិញទៀត ភពផែនដីក្តី សិរីសួស្តីក្តី និងកិរិយាធ្វើឱ្យសម្រេចបានក្តី ត្រូវបានរក្សាគ្រប់គ្រង ហើយថ្ងៃណាដែលអពមង្គលទាំងអស់ក៏ត្រូវបានបញ្ចៀសឱ្យឆ្ងាយទៅ ដោយព្រះ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

អាទិទេពជាអង្គម្ចាស់នៃយើងរាល់គ្នា តាមរយៈព្រះបាទាទាំងគូផង ព្រះឱរផង និងព្រះឱស្ឋផង រហូតដល់មានសេចក្តីសុខក្សេមក្សាន្តយ៉ាងក្រៃលែង ព្រះកិត្តិគុណ ឬភាពល្បីល្បាញយ៉ាងនេះ គេបានពោល ប្រដូចទៅនឹងព្រះរាជាអង្គឯណា។

៤.ព្រះរាជា ព្រះបាទស្រីឦសានវរ្ម័ន (អង្គនោះ) មានជ័យជម្នះ ទ្រង់ជាស្តេចដ៏ចម្បងលើផែនដី ព្រះរាជអំណាចរបស់ទ្រង់ ត្រូវបានប្រទេសជិតខាងទាំងឡាយគោរពកោតខ្លាចដោយសិរសា ទ្រង់មានវីរភាពដ៏ខ្លាំងក្លាក្រៃលែង ជាស្តេចដែលជាម្ចាស់លើគេតែមួយព្រះអង្គគត់ នៅលើដែនដីសុវណ្ណភូមិ ដែលលាតសន្ធឹងរហូតដល់ឆ្នេរសមុទ្រ ។

៥. រីឯសេវកាមាត្យរបស់ព្រះអង្គនាម វៀងគត្ត ដោយការសម្គាល់ចាំទុកឱ្យសមតាមការចង្អុលបង្ហាញនៃគ្រូរបស់ខ្លួន (បានប្រតិស្ឋាន) នូវ (ព្រះបដិមា) ព្រះស្រីបុស្ករេស (ព្រះសិវ) ដែលជាអាទិទេពទី១ នៃទេពទាំងឡាយ ត្រង់កន្លែងបុព្វជនដែលធ្លាប់បានកសាងតាំងពីយូរលង់ណាស់មកហើយនេះ។

៦. ដើម្បីជាការសម្តែងពីភក្តីភាពរបស់ខ្លួនចំពោះគ្រូ គាត់ក៏បានប្រតិស្ឋាននូវព្រះបដិមាព្រះស្រីសង្គោវិន្ទៈ (ព្រះវិស្ណុ) និងព្រះនាងភគិនី (ភរិយា គឺព្រះនាងលក្ស្មី) នៃព្រះមុរារិ (ព្រះវិស្ណុ), ភោគទ្រព្យរួមរបស់ទេវតា (ទាំងបី) គឺព្រះនាងស្វយម្ភុទេវី (ព្រះនាងលក្ស្មី) ព្រះភវ (ព្រះសិវ) និងព្រះកេសវ (ព្រះវិស្ណុ) ក៏ត្រូវបានប្រមូលរៀបចំទុកដាក់ត្រួតពិនិត្យយ៉ាងល្អដោយគាត់ផងដែរ។

៧. ចំនួន (ភោគទ្រព្យ) សម្រាប់បម្រើការទាំងឡាយ ដល់ទេពទាំងអស់នោះក្នុងទេវស្ថាននេះ សរុបគឺមាន គោ ៣០០ក្បាល ព្រមទាំងក្របីសម្រាប់ធ្វើស្រែ ៣០ ក្បាល និងសួនបន្លែដោយឡែកៗនោះចំនួន ៣។

៨. (ភោគទ្រព្យ) សម្រាប់ទេវតាទាំងឡាយបានមកអំពីសេវកាមាត្យនាម វៀងគត្ត នេះ មាន គោ ដី និងទ្រព្យធនទាំងឡាយរបស់ជីដូនជីតា សព្វសារពើ និងភាពរុងរឿងទាំងឡាយក្នុងប្រយោជន៍ជាធម៌ទាំងអម្បាមាននេះ (ប្រៀបបានដូចជា) ប្រទីបមួយដើមក្នុងវង្សត្រកូលរបស់ខ្លួន (ហើយបំភ្លឺ) លើមាគ៌ានៃវង្សត្រកូលទាំងឡាយ។

៩. នរជនណា ព្រោះសេចក្តីលោភលន់ បាននាំយកទៅ ដោយការផ្លាស់ប្តូរ ឬការបំផ្លាញក្តីនូវទ្រព្យធននៃទ្រព្យដែលជាចលនវត្ថុ ឬអចលវត្ថុទាំងឡាយរបស់ទេវតាទាំងបីព្រះអង្គ ដែលបានបូជា និងបរិច្ចាគហើយក្នុងទីនេះ នរជននោះ (បន្ទាប់អំពីស្លាប់ទៅ) នឹងត្រូវធ្លាក់ទៅកើតក្នុងស្ថាននរក រួមជាមួយនឹងជនដែលបានរួមគំនិតផងដែរ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

១០. កាលឆ្នាំនៃស្ដេចសក បានកន្លងទៅហើយ ៥៥៥ ឆ្នាំ (វាណ-ឥឞុ-គរ) ខាងដើមរាត្រី ខាងខ្នើតខែចេត្រ ព្រះចន្ទ្រសោយឫក្ស អគ្និនីនក្សត្រ ដោយផ្ដើមគោចរចេញពីតុលារាសី រហូតទៅដល់មិថុនរាសី ។

១១ .ខណៈពេលសុភលគ្នដ៏ល្អ ដែលកំពុងស្ថិតតាមលំដាប់ចាប់ពី មីនៈរាសី មេសៈរាសី ធនុរាសី រហូតចាប់យកកន្លងវិថីនៃកុម្ភៈរាសី ចំពេលព្រះសុរិយារះឡើង គេបានបូជាថ្វាយ តាមពិធីកម្មរួចហើយ ក៏បានប្រតិស្ឋានទូវព្រះបដិមាព្រះស្រី (ព្រះនាងលក្ស្មី) ព្រះហរ (ព្រះសិវ) និងព្រះក្រឹស្ណ (ព្រះវិស្ណុ) ទាំងនោះក្នុងទេវស្ថាននេះ ។

## វចនាធិប្បាយ

*ស្លោកទី១*

***ជយតិ*** = រមែងឈ្នះ,រមែង-តែង-តែងតែ..មានជ័យជម្នះ ..។

***អធីឝៈ*** (អធិ+ឦឝៈ) = អធិបតី, ដ៏ចម្បងលើគេ..។

***សុរមៅលិកូដចូឌាមណីនិ***

***សុរ*** = ទេព, ទេវតា...។

***មៅលិ*** = ផ្នួងសក់, មកុដ, ចុងប៉ូច...។ល។

***កូដ*** = ភ្នំ, កំពូល, ចុង, រៀច, ប្រហើន..។ល។

***ចូឌាមណីនិ*** = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ..ប្រភេទត្បូងម្យ៉ាង, ត្បូងដែលបំពាក់លើកំពូល ឬទីខ្ពស់ ។

***វិស្ផុរតិ*** = បានផ្សាយទៅហើយ, បានចែងចាំងហើយ, បានផ្សាយទៅពាសពេញហើយ.. ។

***ឧទ្ទយូខានិ*** =ភ្លឺផ្លេក, រស្មីចែងចាំង, ពន្លឺឈ្វេលឆ្វាត់...។ល។

***វិជិត្យ*** = បានឈ្នះហើយ, បានមានជ័យជម្នះហើយ ។

***តតិ*** = នោះ ។ល។

***មូទ្ធំសុ*** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្ដា-លើ-ទាប-ជិត...ក្បាល, កំពូល, សីសៈ..។ល។

***យស្យ*** = អត្ថក្នុងបម្ពី នៃ-របស់ ។ល។ ហើយប្រើក្នុងអត្ថចតុថីមាន ដល់-ដើម្បី-បម្រុង-នឹង-ចំពោះ...ក៏បានដូចគ្នា។

***បាទនខប្រភា***

**បាទ** = បាទជើង ។

**នខ** = ក្រចក, ព្រះនខា ។

**ប្រភា** = ពន្លឺ, រស្មី,

**អារិច្ចិត** = បានធ្វើឱ្យដូច, ប្រដូច, ស្នង, ជាប់...។ល។

**ចន្ទ្រកាន្តិះ** = រស្មី ឬ ពន្លឺ របស់-នៃព្រះចន្ទ្រ ។

*ស្លោកទី២*

**ត្រីឝានវិស្ណុ** (ត្រី ឦឝាន+វិស្ណុ, ប្រថមា ទ្វិវចនៈ)

**ត្រី** = សិរីសួស្តី, ប្រសើរ, ព្រះ, ព្រះអង្គ, សិរី, រុងរឿងចម្រើន, ព្រះនាងលក្ស្មី, រូបសម្រស់, សោភណភាព.. ។ល។

**ឦឝាន** = ព្រះសិវៈ, ព្រះឥសូរ, ទិសឦសាន..។ល។

**វិស្ណុ** = ព្រះវិស្ណុ..។ល។

**ជយតះ** = រមែងឈ្នះ,រមែង-តែង-តែងតែ..មានជ័យជម្នះ ទាំងពីរនាក់ ឬ ទាំងពីរព្រះអង្គ។

**សុរេឝៅ** (សុរ+ឦឝ) = ទេវតាជាធំ ឬជាអធិបតីទាំងពីព្រះអង្គ...។ល។

**យយោះ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ទាំងពីរឯណា.. ។

**ឝរីរាទ្ធសមាគមេន** (ឝរីរ+អទ្ធ+សមាគម)

**ឝរីរ** = សរីរៈ, កាយ, រាងកាយ...។ល។

**អទ្ធ** = ពាក់កណ្តាល, មួយចំហៀង..។ល។

**សមាគមេន** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ..ការរួមផ្សុំផ្គុំ, ការរួមបញ្ចូលគ្នា...។ល។

**អារិះ** =ការស្នង, ការចូលរូប, ការស្ថិតក្នុងខ្លួន..។ល។

**វ្ភូវ (ពភូវ)** = បានមានហើយ, បានកើតឡើងហើយ ។ល។

**អមរមាណវេបុ** (អមរ+មាណវ)

**អមរ** = ដែលមិនស្លាប់, ដែលអមតៈ..។ល។

**មាណវេបុ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទាប-ជិត.. មាណព, ក្មេងកំលោះ,បុរសកំលោះ..។ល។

**វិភុត្វមិ** = ភាពមានអំណាចខ្លាំងក្លា, ភាពជាធំក្រៃលែង..។ល។

អត្ថបទដោយៈ កំ វណ្ណារ៉ា

**ឯកត្វមិ** = ភាពតែម្យ៉ាង, ឯកភាព, ភាពតែមួយ..។ល។

**អនេកតា** = ភាពយ៉ាងច្រើនអនេក, ភាពយ៉ាងសម្បូរបែប, ភាពគ្រប់សព្វ..។ល។

**ច** = ផង, ក្ដី, ក៏, ឬក៏, ថែមទាំង..។ល។

**ស្លោកទី៣**

**វក្ត្រេណ** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...ព្រះឱស្ឋ, ព្រះភក្ត្រ ឬ មុខ ។ល។

**ធីះ** =ការធ្វើឱ្យសម្រេច, ការទ្រទ្រង់, ប្រាជ្ញា ..។ល។

**ឝ្រីះ** = សិរីសួស្ដី, ប្រសើរ, ព្រះ, ព្រះអង្គ, សិរី, សេចក្ដីរុងរឿងចម្រើន, ព្រះនាងលក្ស្មី, រូបសម្រស់, សោភណភាព.. ។ល។

**ឧរសា** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ..ទ្រូង ឬ ព្រះឱរា ។ល។

**ច** = ផង, ក្ដី, ក៏, ឬក៏, ថែមទាំង..។ល។

**បទ្ភ្យាមិ** =ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ..ជើង ឬ ព្រះបាទាទាំងពីរ ។ល។

**ភូះ** = ផែនដី, ពិភពលោក ..។ល។

**បាលិតា** = ត្រូវបានរក្សា, ត្រូវបានគ្រប់គ្រង, ត្រូវបានគ្រប់គ្រងរក្សា, ត្រូវបានកាន់កាប់.. ។ល។

**អស្មត្** = នៃ-របស់ យើង ។

**បតិនា** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...លោកម្ចាស់, អង្គម្ចាស់, ប្ដី, អ្នកធំ.. ។ល។

**អតិភាត្យាតិ** = អំពី-ចាក-ចាប់តាំងអំពី-រហូតដល់-ព្រោះ...សេចក្ដីសុខក្សេមក្សាន្តយ៉ាងក្រៃលែង, ដោតវាសនាដ៏ចម្បង, ព្រេងសំណាងដ៏ធំធេង..។ល។

**ក្ឞិប្តា** = បាន-ត្រូវបាន ដាក់ចុះ, បញ្ជៀស, ទុក ។ល។

**ហិ** = ពិត, ពិតណាស់ ។ល។

**ទូរមិ** = ឆ្ងាយ ។ល។

**យទ៑** = ណា, ឯណា ។

**អហានិ** = ថ្ងៃ, ទិវា, ទិវារាត្រី ..។ល។

**តុ** = ថែម, បន្ថែម, ថែមទាំង, ទោះបី, ប៉ុន្តែ, មួយវិញទៀត, ម្យ៉ាងវិញទៀត ។ល។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

***អឝន្យា*** = អកុសល, សំណាងមិនល្អ, សេចក្តីអាក្រក់..។ល។

***យមិ*** = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ...ណា, ឯណា ។ល។

***កីត៌ិ*** = កិត្តិគុណ, ភាពល្បីល្បាញ, ល្បីរន្ទឺ.. ។ល។

***ឧទ្ទិត្យ*** = បានសំដៅហើយ, បានសំដៅទៅរក ឬទៅកាន់ហើយ, បានផ្ដោះត្រង់ហើយ..។

***វទេត*** = បានពោលហើយ, បាននិយាយហើយ, បានស្តីហើយ, បានប្រាប់ហើយ ..។ល។

***ឥតិ*** = ដូច្នេះ, យ៉ាងនេះ, ដោយប្រការយ៉ាងនេះ, ថា, គឺ, ជា..។ល។

***ឥវ*** = ដូច, ប្រដូច, ស្រដៀង, ត្រូវនឹងគ្នា, ប្រៀបបាននឹង ...។ល។

*ស្លោកទី២*

***សមុទ្របយ៌្យន្តសុវណ៌្ណភូមិ***

***សមុទ្រ*** = សមុទ្រ, សាគរ..។ល។

***បយ៌្យន្ត*** = ឆ្នេរ, ច្រាំង, ទីចុងបំផុត, ចំណុចដែលលាតសន្ធឹងទៅដល់, ព្រំសីមា...។ល។

***សុវណ៌្ណភូមិ*** = ដែនដីមាស, ផ្ទៃដីមាស, តំបន់មាស..។ល។

***ប្ឫថ្វ៉េករាជេន្ទ្របរាក្រមគ្រីះ***

***ប្ឫថ្វ*** = ខ្ពង់, ទួល, លើ...។ល។

***ឯក*** = មួយ, ម្នាក់, មួយព្រះអង្គ..។ល។

***រាជ*** = ព្រះរាជា, ស្តេច, ក្សត្រិយ៍..។ល។

***ឥន្ទ្រ*** = ជាធំ, ជាអធិបតី, ទេពដែលជាអធិបតី..។ល។

***បរាក្រម*** = ខ្លាំងក្លា, ក្លាហាន, វីរភាព..។ល។

***គ្រីះ*** = សិរីសួស្តី, ប្រសើរ, ព្រះ, ព្រះអង្គ, សិរី, សេចចក្តីរុងរឿងចម្រើន, ព្រះនាងលក្ស្មី, រូបសម្រស់, សោភណភាព.. ។ល។

***សមស្តសាមន្តគរោឞ្ឫតាជ្ញះ***

***សមស្ត*** = ទាំងអស់, ទាំងឡាយ, ទាំងពួង, គ្រប់សព្វ..។ល។

***សាមន្ត*** = ប្រទេសជិតខាង, តំបន់ជិតគ្នា, ជិត, ប្រកៀកគ្នា..។ល។

***គិរសិ*** = ក្បាល, សីសៈ, ព្រះសិរ..។ល។

***ឧឞ្ឫត*** (ឧទ្ធ្ឫត) = បាន-ត្រូវបាន..លើក, លើកឱ្យខ្ពស់, លើកទូល..។ល។

***អាជ្ញះ*** = អំណាច, អាជ្ញា, ការគ្រប់គ្រង់, ការបង្គាប់បញ្ជា..។ល។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

**ត្រីគានវម៌្មា** (ត្រី ឰគានវម៌្មា) = ព្រះបាទ ត្រី ឰគានវម៌្មន, ព្រះរាជា ស្រី ឰសានវរ្ម័ន ។

**ជយតិ** =រមែងឈ្នះ, រមែង-តែង-តែងតែ..មានជ័យជម្នះ ..។

**ក្សិតីគះ** (ក្សិតិ+ឰគៈ) = ជាធំលើផែនដី, ជាអធិបតីលើផែនដី, ជាចម្បងលើពិភពលោក..

*ស្លោកទី៥*

**តស្យ =** នៃ-របស់-ដល់-ដើម្បី-សម្រាប់...បុគ្គលឯណា ឬ បុគ្គលនោះ.. ។ល។

**អបិ** = សូម្បី, ទោះបី, ផង, ក្តី, ក៏, ឬក៏, ថែមទាំង..។ល។

**ភ្ឫត្យះ** =អ្នកបំរើ, សេវកាមាត្យ..។ល។

**សមជត្តសំជ្ញាមិ** = ការសម្គាល់ចាំទុកឱ្យសម ...។ល។

**ព្រៀឯត្ត ឥតិ** = បុគ្គលឈ្មោះថា ព្រៀឯត្ត ។

**អាត្មគុរុប្រទិថ្នាមិ** = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ-តាម...ការចង្អុលបង្ហាញ, កាណែនាំ ឬ ការបញ្ជានៃគ្រូរបស់ខ្លួន ។

**តតិ** = នោះ ។ល។

**បូវ៌្វជេ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត...បុព្វជន, ជីដូនជីតា, អ្នកជំនាន់មុន, បង...។ល។

**ស្ថាបិតវតិ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត...ដែលបានកសាង, ដែលបាន ប្រតិស្ឋាន, ដែលបានតំកល់...។ល។

**អនាទិមិ** = តាំងពីយូរលង់ណាស់មកហើយ, មិនដឹងទីចាប់ផ្តើម, មិនដឹងពេលផ្តួចផ្តើម, មិនដឹងតាំងអំពីកាលណាមក, តរៀងមក...។ល។

**ត្រី បុស្ករេគមិ** = ព្រះស្រីបុស្ករៈដ៏ចម្បង..។ល។

**ប្រថមមិ** = ជាទី១, ជាដំបូង, ជាបឋម...។ល។

**សុរាណាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ទេវតាទាំងឡាយ។

*ស្លោកទី៦*

**គុរោះ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...គ្រូ ឬ អាចារ្យ ។

**ស្វភក្ត្យា** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...ភក្តីភាព, សេចក្តីគោរព, សេចក្តីស្មោះត្រង់, សេចក្តីស្រលាញ់ស្មោះស្ម័គ្រ...របស់ខ្លួន ។ល។

**ភគិនិមិ** = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ..បងប្អូនស្រី, ភរិយា, ប្រពន្ធ, ព្រះនាងលក្ស្មី..។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

**មុរារេះ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ព្រះវិស្ណុ..ៗលៗ

**ត្រី គ(ស)រ្វំគោវិន្ទមិ** = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ... ព្រះស្រីសវ៌គោវិន្ទៈ ៗលៗ

**អតិច្ឋិបត៏** = បានប្រតិស្ថានហើយ, បានតំកល់ហើយ, បានតាំងទុកហើយ, បានកសាងហើយ... ៗលៗ

**សះ** = គាត់ ឬ គេនោះ ៗលៗ

**ស្វយម្ភុទេវីភវកេឝវានាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ព្រះនាងស្វយម្ភុទេវី(ព្រះនាងលក្ស្មី), ព្រះភវ(ព្រះសិវៈ) និងព្រះកេសវៈ(ព្រះវិស្ណុ) ។

**តេន** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...គាត់ ឬ គេនោះ

**អបិ** = សូម្បី, ទោះបី, ផង, ក្តី, ក៏, ឬក៏, ថែមទាំង..ៗលៗ

**សំស្ថាបិតះ** = ត្រូវបាន..ប្រមូល, រៀបចំ, ទុកដាក់, ត្រួតពិនិត្យ, តំកល់ឱ្យល្អ...ៗលៗ

**ឯកភោគះ** = ភោគៈទ្រព្យរួម, ភោគៈរួមតែមួយ..ៗលៗ

ស្លោកទី៧

**តេភ្យោមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...គេ, គាត់ ឬ ទេពទាំងឡាយនោះៗ

**សុរាណាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ទេព ឬ ទេវតាទាំងឡាយ ។

**ឥហ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត...ទីនេះ, ទីស្ថាននេះ, កន្លែងនេះ..ៗលៗ

**ភុត្យសំខ្យា** = ចំនួននៃទ្រព្យ, មនុស្ស, សត្វសម្រាប់បម្រើការទាំងឡាយ ៗលៗ

**សំបិណ្ឌិតា** = សរុប, សង្ខេប, ពួនផ្តុំ, គួបផ្តុំ, រួមសរុប...ៗលៗ

**ស្យាត៏** = បានមានហើយ..ៗលៗ

**ត្រិឝតី** = ចំនួន ៣០០ ។

**គវាំ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...គោទាំងឡាយ

**ច** = ផង, ក្តី, ក៏, ឬក៏, ថែមទាំង..ៗលៗ

**ត្រឹឝតី** = ចំនួន ៣០ ។

**ក្សេត្រកមាហិឞាណាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ក្របីទាំងឡាយ សម្រាប់ធ្វើស្រែ..ៗលៗ

**ប្រត្យេកមិ** = ចំណែក, ដោយឡែកៗ, វគ្គ, តែមួយៗ, នីមួយៗ..ៗលៗ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

**អារាម** = សួន, សួនច្បារ, សួនដំណាំ, សួនផ្កាបន្លែផ្លែឈើ, អារាម, ទីអាស្រម, ទីអាវាស.. ។ល។

**ឥតិ** = ដូច្នេះ, យ៉ាងនេះ, ដោយប្រការយ៉ាងនេះ, ថា, គឺ, ជា..។ល។

**ត្រយាណាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ចំនួន ៣។

*ស្លោកទី៨*

**ឯតានិ** = ទាំងឡាយនេះ, ទាំងអស់នេះ..។ល។

**គោភូធនបូវ្វកានិ** =(គោ+ភូ+ធន+បូវ្វក)

គោ ដី និង ទ្រព្យធនទាំងឡាយរបស់ជីដូនជីតា ឬ អ្នកជំនាន់មុន។

**សវ្វាំណិ** = សព្វគ្រប់, សព្វគ្រប់ទាំងអស់, សព្វសារពើ...។ល។

**ធម្មាត្ថមិ** (ធម៌+អថ៌) = នូវ-កាន់-ញាំង-អស់-នឹង-ចំពោះ-ដោយ-ក្នុង ...ប្រយោជន៍ជាធម៌.. ។ល។

**ឧបាជ្ជិតានិ** = ភាពបានរុងរឿងទាំងឡាយ, ភាពភ្ញីផ្សាយទៅទាំងឡាយ..។ល។

**បទេ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្ដា-លើ-ទៀប-ជិត...ចំណែកជាគ្រឿងដល់,មាគ៌ា, ផ្លូវ, ជំហាន, បទ...។ល។

**កុលានាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ត្រកូល ឬ ពូជពង្សទាំងឡាយ..។ល។

**ស្វកុលៃកទីបះ** (ស្វ-កុល-ឯក-ទីប) = ប្រទីបមួយដើមក្នុងវង្សត្រកូលរបស់ខ្លួន ។

**ព្រៀឯត្ត នាមាត៑** = អំពី-ចាក-ចាប់តាំង-រហូតដល់-ហេតុ-ព្រោះ...ជនឈ្មោះ ព្រៀឯត្ត ។

**ឥតះ** = អំពី..នេះ, ខាងមុខនេះ, ក្នុងនេះ...។ល។

**ទេវតាភ្យះ** = អំពី-ចាក-ចាប់តាំង-រហូតដល់-ហេតុ-ព្រោះ-ដល់-ដើម្បី-បម្រុង-សម្រាប់.... ទេវតាទាំងឡាយ។

*ស្លោកទី៩*

**យជ្វា** = បានថ្វាយហើយ, បានបូជាហើយ..។ល។

**ត្រយាណាមិ** =នៃ-របស់-ដល់-ដើម្បី-សម្រាប់...ទាំងបី ៣ ។

**ឥហ** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្ដា-លើ-ទៀប-ជិត...ទីនេះ, ទីស្ថាននេះ, កន្លែងនេះ..។ល។

**ទេវតានាមិ** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...ទេព ឬ ទេវតាទាំងឡាយ ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

***ទត្វា*** = បានឱ្យហើយ, បានបរិច្ចាគហើយ..។

***ធនមិ*** = នូវ-កាន់-ញាំង-អស់-នឹង-ក្នុង-ដោយ-ចំពោះ...។ល។

***យះ*** = ជន ឬ បុគ្គលឯណា ។

***ហរតិ ស្ម*** = បាននាំយកទៅហើយ, បានលួចទៅហើយ..។ល។

***លោភាត៑*** = ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...សេចក្តីលោភលន់, បំណងចង់បាន, ការជំពាក់ចិត្ត..។ល។

***សហ*** = ជាមួយ, រួមជាមួយ, មួយអន្លើ...។ល។

***ប្រសូត្យា*** = ដោយកើតជាមួយ, កើតរួមជាមួយ..។ល។

***និរយេ*** = ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត...ស្ថាននរក ។

***និមជ្ជេត៑*** = ត្រូវ-នឹងត្រូវ-គប្បី-គួរតែ..ធ្លាក់ចុះ, ប្រមុចចុះ...។ល។

***អាសំ*** = នូវ-កាន់-ញាំង-អស់-នឹង-ក្នុង-ដោយ-ចំពោះ...ការបំបែក, ការបំផ្លាញ, ការប៉ះទង្គិចឱ្យខូច...។ល។

***ច្វាត៑*** = អំពី-ចាក-ចាប់តាំង-រហូតដល់-ហេតុ-ដោយ-ព្រោះ...ការផ្លាស់ប្តូរ, ការយកពីកន្លែងមួយទៅកាន់កន្លែងមួយទៀត, លោត, ផ្លោះ...។ល។

***ស្ថាវរជង្គមនាមិ*** = នៃ-របស់-ដល់-ដើម្បី-សម្រាប់...វត្ថុដែលមានចលនា និង គ្មានចលនា, វត្ថុដែលអាចនាំយកទៅបាន និង មិនអាចនាំយកទៅបាន, ចលនវត្ថុ និង អចលវត្ថុទាំងឡាយ ។

*ស្លោកទី១០*

*សមា គកេន្ទ្រស្យគរេឥបុវាណៃះ វ្យិតិគ្គ៌តា*

***សមា***= ឆ្នាំ, វស្សា, វត្សរ៍ ។

***គកេន្ទ្រស្យ*** = នៃ-របស់..ស្តេចសកៈ ។

***គរ***= ព្រួញ, លេខ៥...។ល។

***ឥបុ*** = ព្រួញ, លេខ៥...។ល។

***វាណៃះ*** = ព្រួញ, លេខ៥...។ល។

***វិតិគ្គ៌តា*** = បានកន្លងទៅហើយ, បានហួសទៅហើយ ...។ល។

ឆ្នាំនៃស្តេចសកៈ បានកន្លងទៅហើយ ៥៥៥ ឆ្នាំ (វាណា-ឥបុ-គរ)។

***ចៃត្រសិតាទិរាត្រិះ*** = ខាងដើមរាត្រី ខាងខ្នើតខែចេត្រ ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

***យទា*** = *ពេលណា, ថ្ងៃណា..។*

***អគ្និទីសីតកពោនុយាត្រិ*** =*ព្រះចន្ទ្រសោយឫក្ស អគ្និទីនក្សត្រ ។*

***តុលោទយះ*** = *តុលារាសីងើបឡើង ឬ រះឡើង..។ល។*

***មៃថុនភាគយុក្តះ*** = *ដល់ព្រម-ប្រកបដោយភាគមៃថុនរាសី ឬ មិថុនរាសី..។ល។*

*ស្លោកទី១១*

***មីនាជវិនោឈមមាគ៌កុម្ភ ចាបក្រមស្ថា គុកលគ្ន ទាស្តេ*** = *ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត....ខណៈពេលសុកលគ្នដ៏ល្អ ដែលកំពុងស្ថិតតាមលំដាប់ចាកពី មីនៈរាសី មេសៈរាសី ធនុរាសី រហូតចាប់យកកន្ទង់វិថីនៃ កុម្ភៈរាសី ។*

***សូយ៉ោទយះ*** (*សូយ៌+ឧទយះ*) = *ព្រះសុរិយារះឡើង, ព្រះអាទិត្យរះឡើង, ព្រះសុរិយោទ័យ...។ល។*

***គ្រីហរក្ឫ្ណម្ភមូត្តីមិ*** (*គ្រី+ហរ+ក្ឫ្ណ+មូត៌ិ*) = *នូវ-កាន់-ញាំង-អស់-នឹង-ក្នុង-ដោយ-ចំពោះ...ព្រះបដិមា ព្រះស្រី (ព្រះនាងលក្ស្មី) ព្រះហរៈ (ព្រះសិវៈ) ព្រះក្រឹស្ណៈ (ព្រះវិស្ណុ) ។*

***អតិប្ឋិបតិ*** = *បានប្រតិស្ថានហើយ, បានតំកល់ហើយ, បានកសាងហើយ...។ល។*

***តានិ*** = *នូវ-កាន់-ញាំង-អស់-នឹង-ក្នុង-ដោយ-ចំពោះ...ទាំងនោះ ។*

***វិធិនា*** = *ដោយ-ដោយសារ-ព្រោះ-ព្រោះតែ-ហេតុ-ដោយហេតុតែ...ពិធីកម្ម, បែបកិច្ចការ, របៀបធ្វើ..។ល។*

***ឥហ*** = *ក្នុង-ឰដ៏-ត្រង់-ជុំនុំ-បណ្តា-លើ-ទៀប-ជិត...ទីនេះ, ទីស្ថាននេះ, កន្លែងនេះ..។ល។*

***យជ្វា*** = *បានបូជាហើយ, បានថ្វាយហើយ..។ល។*



រូបលេខ២១៖ ទីតាំងវត្តគិរីស្តេចគង់ ដែលជាអតីតប្រាសាទបុរាណនៅស.វ.ទី៧ (រូបថត៖ ខេង សុខឡេង)



រូបលេខ២២៖ ស្លាកស្នាមឥដ្ឋប្រាសាទបុរាណនៅស.វ.ទី៧ មុនការធ្វើកំណាយ (រូបថត៖ ខេង សុខឡេង)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ ក្រដាសផ្ដាមសិលាចារឹកសំស្រ្កឹតនៅវត្តគិរីស្តេចគង់

អត្ថបទដោយ៖ កំ វណ្ណារ៉